**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ២៦៥៤/២៣ មស.សជណ

# សេចក្តីជូនដំណឹង

- យោងសេចក្តីសម្រេចលេខ ១៧៩៩/២៣ មស.សសរ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ
- យោងសេចក្តីជូនដំណឹងលេខ ១៨៨៣/២៣ មស.សជណ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ
- យោងសេចក្តីជូនដំណឹងលេខ ២៤៥៥/២៣ មស.សជណ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ។

គណៈកម្មការរៀបចំការប្រឡងប្រជែងនៃក្រសួងមុខងារសាធារណៈ សូមជម្រាបជូនដំណឹងដល់បេក្ខជនជាសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ដែលបានដាក់ពាក្យស្នើសុំសិទ្ធិប្រឡងប្រជែង និងទទួលបានសលាកបត្រឯកត្តជន ដើម្បីចូលរួមប្រឡងប្រជែងក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០២៣ ឱ្យបានជ្រាបថា គណៈកម្មការរៀបចំការប្រឡងប្រជែង បានសម្រេចដូចខាងក្រោម៖

**១. កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅ ថ្ងៃសៅរ៍ ទី២៧ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ០៨:០០នាទី ព្រឹក**

**២. មណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) អគារ T "សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន" ទល់មុខទីលានបាល់ទាត់**

**៣. វិញ្ញាសាប្រឡងប្រជែង ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យមុខងារសារធារណៈ មុខវិជ្ជាភាសាអង់គ្លេស និងមុខវិជ្ជាកុំព្យូទ័រ រយៈពេល ០១ម៉ោង ៣០នាទី សម្រាប់ប្រភេទក្របខ័ណ្ឌ ក ខ និង គ**

**៤. បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងយ៉ាងយូរត្រឹម វេលាម៉ោង ០៧:០០នាទី ព្រឹក ជាក់ហិត និងសូមភ្ជាប់មកជាមួយនូវសលាកបត្រឯកត្តជន ដែលបានផ្តល់ជូនដោយគណៈកម្មការរៀបចំការប្រឡងប្រជែង**

**៥. បេក្ខជនអាចទៅពិនិត្យការបិទផ្សាយបញ្ជីឈ្មោះ លេខបន្ទប់ ប្លង់មណ្ឌលប្រឡង កម្មវិធីប្រឡងប្រជែង និងបទបញ្ញត្តិ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) នៅថ្ងៃសុក្រ ទី២៦ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទី ព្រឹក។**

អាស្រ័យហេតុនេះ សូមបេក្ខជនជាសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិល ជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០២៣
**រដ្ឋលេខាធិការ និងជា**
**ប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង**

**អែម ប៊ុនធុល**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  " ដើម្បីជូនជ្រាប "
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងផែនការ
- ក្រសួងយុត្តិធម៌
- ក្រសួងទេសចរណ៍
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
  " ដើម្បីសហការអនុវត្ត និងជួយផ្សព្វផ្សាយ "
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

## បទបញ្ញត្តិ

## សម្រាប់បេក្ខជនប្រឡងប្រជែងចូលបម្រើការងាររដ្ឋ ក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ឆ្នាំ២០២៣

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងវិន័យនៅក្នុងពេលប្រឡងប្រជែងឱ្យប្រព្រឹត្តទៅបានល្អប្រសើរ បេក្ខជនត្រូវគោរពតាមបទប្បញ្ញត្តិនៃការប្រឡងប្រជែង ដូចខាងក្រោម៖

**១. ប្រការដែលបេក្ខជនមិនត្រូវអនុវត្តក្នុងមណ្ឌលប្រឡង**

- ហាមដាច់ខាតយកអាវុធ ឬ គ្រឿងផ្ទុះគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡង
- ហាមយក និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទង និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡង
- មិនត្រូវឱ្យអ្នកដទៃប្រឡងប្រជែងជំនួសឡើយ
- ហាមធ្វើសកម្មភាពណាមួយដែលផ្តល់ការរំខានដល់បេក្ខជនប្រឡងប្រជែងផ្សេងទៀត
- ហាមចម្លងចម្លើយពីបេក្ខជនជិតខាង ឬ បង្កលក្ខណៈឱ្យបេក្ខជនដទៃចម្លង ឬ សរសេរហើយអានខ្លាំងៗឮដល់បេក្ខជនដទៃទៀតក្នុងពេលកំពុងធ្វើប្រធានវិញ្ញាសា
- ហាមប្តូរសន្លឹកកិច្ចការប្រឡងប្រជែង ដើម្បីឱ្យបេក្ខជនដទៃជួយកែ
- ហាមជជែក ឬពិភាក្សាគ្នាក្នុងពេលដំណើរការប្រឡងប្រជែង
- ហាមប្រើប្រាស់ប៊ិកដែលអាចលុបបាន
- ហាមប្រើប្រាស់ទឹកលុប ដើម្បីលុបកំហុសផ្សេងៗលើសន្លឹកកិច្ចការប្រឡងប្រជែង
- មិនត្រូវធ្វើសញ្ញាសម្គាល់ណាមួយ ដល់អនុគណៈកម្មការនានា ក្នុងដំណើរការប្រឡងប្រជែង
- ក្នុងករណីរកឃើញថា បេក្ខជនណាម្នាក់មានចេតនាប្រព្រឹត្តបទល្មើសណាមួយ ដែលបង្កអសន្តិសុខដល់ដំណើរការប្រឡងប្រជែង ឬផ្ទុយពីបទប្បញ្ញត្តិដែលបានចែងខាងលើ គណៈកម្មការរៀបចំការប្រឡងប្រជែងមានសិទ្ធិបញ្ឈប់ការប្រឡងប្រជែងរបស់បេក្ខជន ឬឱ្យបេក្ខជននោះធ្លាក់ដោយស្វ័យប្រវត្តិ។

**២. ប្រការដែលបេក្ខជនត្រូវអនុវត្តក្នុងពេលប្រឡងប្រជែង**

- ត្រូវទៅពិនិត្យមើលឈ្មោះ លេខតុ លេខបន្ទប់ និងអគារប្រឡងរបស់ខ្លួននៅតាមមណ្ឌលប្រឡងមុន ០១ថ្ងៃ នៃកាលបរិច្ឆេទប្រឡងប្រជែងដែលបានកំណត់
- ត្រូវមកដល់មណ្ឌលប្រឡង រយៈពេល ០១ម៉ោង មុនពេលចាប់ផ្តើមដំណើរការប្រឡងប្រជែងធ្វើប្រធានវិញ្ញាសាដំបូង
- ត្រូវស្លៀកសំលៀកបំពាក់ និងរៀបចំអាកប្បកិរិយាឱ្យបានសមរម្យ
- ត្រូវយកមកជាមួយនូវ សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ឆាយា (ព្រះសង្ឃ)



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

- ត្រូវអនុវត្តតាមការណែនាំរបស់អនុគណៈកម្មការមេប្រយោគ និងអនុគណៈកម្មការអនុរក្សតាមបន្ទប់
- ត្រូវចូលរួមសហការ និងបង្កភាពងាយស្រួល ដល់អ្នកមានសមត្ថកិច្ចត្រួតពិនិត្យ ក្នុងការដកហូតនូវសម្ភារ ឬរបស់របរផ្សេងៗដែលមិនអនុញ្ញាតឱ្យយកចូលក្នុងមណ្ឌលប្រឡង និងបន្ទប់ប្រឡង
- ត្រូវរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងភាពស្ងៀមស្ងាត់នៅក្នុងពេលប្រឡងប្រជែង
- បេក្ខជនត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន និងត្រូវអង្គុយតាមលេខតុដែលអនុរក្សតាមបន្ទប់បានបែងចែកជូន
- ត្រូវពិនិត្យប្រធានវិញ្ញាសាអំពីចំនួនទំព័រ ចំនួនសំណួរ និងរយៈពេលធ្វើវិញ្ញាសាឱ្យបានច្បាស់លាស់ ដើម្បីឱ្យប្រាកដថាមានសំណួរគ្រប់ចំនួន និងត្រឹមត្រូវ ទៅតាមប្រភេទក្របខ័ណ្ឌដែលបេក្ខជនបានជ្រើសរើស មុនពេលចាប់ផ្តើមធ្វើប្រធានវិញ្ញាសា
- ត្រូវពិនិត្យក្បាលសន្លឹកកិច្ចការ រាល់ព័ត៌មានផ្សេងៗ ដើម្បីបញ្ជាក់ថាជាសន្លឹកកិច្ចការរបស់ខ្លួន និងមានការចុះហត្ថលេខារបស់អនុរក្សក្នុងបន្ទប់ទាំងពីរ
- ត្រូវប្រគល់សន្លឹកកិច្ចការប្រឡងប្រជែង និងប្រធានវិញ្ញាសា ជូនអនុរក្សប្រចាំបន្ទប់វិញ ទោះបីជាសន្លឹកកិច្ចការប្រឡងប្រជែងនោះ មិនបានសរសេរអ្វីក៏ដោយ
- **ត្រូវយល់ដឹងពីអត្ថន័យនៃសំឡេងជួងៈ**
  - ***ជួងទី១ ៖** បេក្ខជនត្រូវចូលក្នុងបន្ទប់ប្រឡង ដើម្បីចុះហត្ថលេខាលើបញ្ជីវត្តមាន និងសន្លឹកកិច្ចការ
  - ***ជួងទី២ ៖** ចាប់ផ្តើមធ្វើប្រធានវិញ្ញាសា
  - ***ជួងទី៣ ៖** នៅសល់ ១៥(ដប់ប្រាំ) នាទីទៀត ដល់ម៉ោងប្រមូលសន្លឹកកិច្ចការ
  - ***ជួងទី៤ ៖** បេក្ខជនត្រូវប្រគល់សន្លឹកកិច្ចការទាំងអស់ដែលបានចែកជូនត្រឡប់មកឱ្យអនុរក្សតាមបន្ទប់វិញជាកំហិត។

☞ **សម្គាល់ៈ**

*ក្នុងករណីសន្លឹកកិច្ចការមិនមែនជារបស់ខ្លួន ឬមានស្ថានភាពខុសប្រក្រតី (រហែក ប្រឡាក់ រលុបនៅផ្នែកណាមួយ) ត្រូវរាយការណ៍ជូនអនុរក្សក្នុងបន្ទប់ ដើម្បីផ្លាស់ប្តូរសន្លឹកកិច្ចការថ្មី

*ក្នុងករណីបេក្ខជនមិនប្រគល់សន្លឹកកិច្ចការប្រឡងប្រជែងជូនអនុរក្សតាមបន្ទប់វិញ ត្រូវចាត់ទុកថាអវត្តមាន

*បេក្ខជនអាចប្តូរសន្លឹកកិច្ចការបានតែមួយដងប៉ុណ្ណោះ ដូចនេះ ស្នើឱ្យបេក្ខជនសរសេរចម្លើយឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍ដែលបានកំណត់។

ថ្ងៃ ពុធ ៥កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ និងជាប្រធាន**

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

**អែម ម៉ុនធុល**

ក្រសួងមុខងារសាធារណៈ
គណៈកម្មការរៀបចំការប្រឡងប្រជែង

**អគារសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (T)**

ប្លង់មណ្ឌលប្រឡងប្រជែង

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ជាន់ទី ៤ | ជណ្ដើរ | | | | | ជណ្ដើរ | ៣២ | | | | ជណ្ដើរ |
| ជាន់ទី ៣ | | ២៤ | ២៥ | ២៦ | ២៧ | | ២៨ | ២៩ | ៣០ | ៣១ | |
| ជាន់ទី ២ | | ១៦ | ១៧ | ១៨ | ១៩ | | ២០ | ២១ | ២២ | ២៣ | |
| ជាន់ទី ១ | | ៨ | ៩ | ១០ | ១១ | | ១២ | ១៣ | ១៤ | ១៥ | |
| ជាន់ផ្ទាល់ដី | | ១ | ២ | ៣ | Center | | ៤ | ៥ | ៦ | ៧ | |

អគារប្រឡងប្រជែង(T)

បន្ទប់អនុគណៈកម្មការកណ្ដាល




ជើង
លិច
កើត
ត្បូង

**ផែនទីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
**Map of Royal University of Phnom Penh**